**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមសម្តែងការសោកស្តាយចំពោះការចែកចាយព័ត៌មានករណីការស្លាប់របស់កម្មការិនីឈ្មោះ **ឆោម សុភាលី** អាយុ ៣៧ឆ្នាំ នៅលើហ្វេសប៊ុកមួយចំនួន កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ នេះ។ ក្រោយពីក្រុមការងារបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) បានធ្វើការងារជាមួយក្រុមគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យកាល់ម៉ែត ក្រសួងសូមបញ្ជាក់ជូនដូចខាងក្រោម៖

១-កម្មការិនីរូបនេះ បានចូលមន្ទីរពេទ្យកាល់ម៉ែតនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ ដោយមានរោគវិនិច្ឆ័យ គឺសដៃស្បូនខាងស្តាំដែលមានទំហំធំ (Kyste de l’ Ovaire Droite Volumineuse Complique’e )។ អ្នកជំងឺនេះទទួលការវះកាត់លើកទី១ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង១២ថ្ងៃត្រង់ ទទួលបានលទ្ធផលល្អ។

២-មកដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ អ្នកជំងឺមានអាការៈថ្មី ដូចជាក្អួតមានឈាម រាគ ពោះឡើងតឹងឈឺ បន្ទាប់មកគ្រូពេទ្យថតពោះ ហើយជាលទ្ធផលគ្រូពេទ្យសន្និដ្ឋានថាមានធ្លាយពោះវៀន ហើយត្រូវធ្វើការវះកាត់លើកទី២ ជាបន្ទាន់ទទួលបានលទ្ធផលភ្លាមៗល្អ។

៣-លុះដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អ្នកជំងឺមានអាការៈកើតឡើងថ្មីម្តងទៀតភ្លាមៗ គឺក្អួតឈាម (Hematemese de Grande Abondant) ពេលនោះទទួលការសង្គ្រោះបន្ទាន់ភ្លាមៗ និងបញ្ចូលឈាម អស់៤ប្លោក។ ដោយស្ថានភាពធ្ងន់ធ្ងរមិនអាចជួយសង្គ្រោះបាន អ្នកជំងឺបានស្លាប់ដោយ Choc Hemoragique។

ជារួម មន្ទីរពេទ្យកាល់ម៉ែតបានព្យាយាមជួយសង្គ្រោះជនរងគ្រោះអស់ពីសមត្ថភាព ប៉ុន្តែដោយសារស្ថានភាពអ្នកជំងឺមានសភាពធ្ងន់ធ្ងរពេកទើបមិនអាចជួយសង្គ្រោះបាន។ ករណីនេះ ក្រុមការងារនៃមន្ទីរពេទ្យកាល់ម៉ែត ក៏បានឆ្លើយបំភ្លឺទៅម្ចាស់គណនីហ្វេសប៊ុករួចរាល់ ហើយក្រុមការងារពហុជំនាញនៃមន្ទីរពេទ្យកាល់ម៉ែតនៅតែស្វាគមន៍រង់ចាំទទួលបកស្រាយនូវសំណួរ និងចម្ងល់ផ្សេងៗ ដើម្បីឱ្យក្រុមការងារបន្តពន្យល់ និងបង្ហាញពីស្ថានភាពជាក់ស្តែងនៃការវិវត្តធ្ងន់ធ្ងរនៃជំងឺនេះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំជាមួយក្រុមគ្រួសារនៃសព។

ទន្ទឹមនឹងនេះ ក្រសួងសង្ឃឹមជឿជាក់ថា អ្នកលេងហ្វេសប៊ុកទាំងអស់នឹងចូលរួមទប់ស្កាត់ការចែកចាយនូវរាល់ព័ត៌មានមិនពិតនានា។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៩

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩